# នីតិវិធីនៃការអនុវត្តដោយបង្ខំ
## “គោលការណ៍នៃការរឹបអូសចលនវត្ថុ”

**សំណួរ៖ តើអ្វីជាការរឹបអូសចលនវត្ថុ?**

- ✓ ជាការអនុវត្តដោយបង្ខំដែលធ្វើឡើងតាមនីតិវិធីដែលអាជ្ញាសាលារឹបអូសយកចលនវត្ថុដែលជាកម្មសិទ្ធិរបស់កូនបំណុលនៃការអនុវត្តដើម្បីសម្រេចសិទ្ធិទាមទារដែលមានគោលបំណងឱ្យសងជាប្រាក់របស់ម្ចាស់បំណុលនៃការអនុវត្ត។
- ✓ ការរឹបអូសអាចធ្វើបានចំពោះ រូបទ្រព្យ ឬអរូបទ្រព្យ ដែលស្ថិតក្រោមកម្មសិទ្ធិ ឬស្ថិតក្រោមការកាន់កាប់របស់កូនបំណុលនៃការអនុវត្តលើកលែងតែមានបញ្ញត្តិចែងផ្សេងពីនេះនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី។



## សំណួរ៖ តើការអនុវត្តការរឹបអូសចលនវត្ថុត្រូវគោរពគោលការណ៍ច្បាប់អ្វីខ្លះ?

- ផ្អែកតាមបញ្ញត្តិក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧គេអាចរកឃើញគោលការណ៍សំខាន់ៗដូចខាងក្រោម៖

**១. ចលនវត្ថុដែលហាមឃាត់មិនឱ្យរឹបអូស៖**

- ទ្រព្យសម្បត្តិសម្រាប់ធានាការចិញ្ចឹមជីវិតក្នុងកម្រិតអប្បបរមារបស់កូនបំណុល
- ទ្រព្យសម្រាប់ធានាការបន្តការងាររបស់កូនបំណុល។
- ទ្រព្យសម្បត្តិដែលត្រូវយកចិត្តទុកដាក់ផ្អែកលើវប្បធម៌ ឬ សង្គម។







**២. ទ្រព្យសម្បត្តិរបស់កូនបំណុល ឬស្ថិតក្រោមការកាន់កាប់របស់កូនបំណុល**

**៣. ការប្តូរទំហំនៃការរឹបអូស**

ទោះបីជាមានការហាមឃាត់មិនឱ្យធ្វើការរឹបអូសនូវចលនវត្ថុមួយចំនួនក៏ដោយក៏ ផ្អែកតាមស្ថានភាពជាក់ស្តែងរបស់កូនបំណុលនៃការអនុវត្ត ឬម្ចាស់បំណុលនៃការអនុវត្ត ពេលខ្លះចាំបាច់ត្រូវផ្លាស់ប្តូរទំហំនៃទ្រព្យដែលហាមឃាត់មិនឱ្យរឹបអូសនេះបាន។

(បន្ត)

### ៤. ការហាមឃាត់ការរឹបអូសហួសប្រមាណ

ការរឹបអូសចលនវត្ថុមិនត្រូវធ្វើឱ្យហួសកម្រិតចាំបាច់សម្រាប់សំណងសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលនៃការអនុវត្ត និងសោហ៊ុយចាំបាច់សម្រាប់ការអនុវត្ត។

### ៥. ការហាមឃាត់មិនឱ្យរឹបអូសក្នុងករណីប៉ាន់ប្រមាណឃើញថាគ្មានចំនួនសេសសល់

អាជ្ញាសាលាមិនត្រូវរឹបអូសឡើយ ប្រសិនបើប៉ាន់ប្រមាណឃើញថាៈ ចំនួនទឹកប្រាក់ដែលបានមកពីការលក់ចលនវត្ថុដែលត្រូវបានរឹបអូសគ្មានចំនួនសេសសល់ក្រោយពីបានបង់សោហ៊ុយសម្រាប់នីតិវិធី។